# ដំណឹងជ្រើសរើសសហគ្រិនកសិកម្មវ័យក្មេង

## សាវតា

អង្គការភាពជាដៃគូដើម្បីចីរភាពវិស័យកសិកម្មកម្ពុជា (CPSA) គឺជាអង្គការដៃគូប្រចាំប្រទេសរបស់ Grow Asia ក្នុងប្រទេសកម្ពុជា ដែលធ្វើការយ៉ាងជិតស្និតជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត ក៏ដូចជាផ្នែកឯកជន និងអង្គការកសិករ។ CPSA ធ្វើការរួមគ្នាជាមួយក្រុមហ៊ុន ភ្នាក់ងាររដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមកសិករ និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីភ្ជាប់កសិករខ្នាតតូច ទៅកាន់ទីផ្សារ។ គោលបំណងរួមគឺដើម្បីបង្កើនប្រាក់ចំណូល និងផលិតភាពរបស់កសិករ ព្រមទាំងជម្រុញឱ្យមាននិរន្តរភាពបរិស្ថានសម្រាប់ការងារកសិកម្ម។ បន្ថែមពីនេះផងដែរ CPSA ក៏កំពុងធ្វើការគាំទ្រក្រុមការងារចំនួន៤មានដូចជា៖ ស្វាយចន្ទី ម្រេច ផ្លែឈើ និងបន្លែ និងសហគ្រាសធុនតូច និងមធ្យមផ្នែក កសិ-អាហារ និងបញ្ហាដទៃសំខាន់ចំនួន៣ទៀត (កសិកម្មតាមកិច្ចសន្យា ការវិនិយោគកសិកម្មប្រកបដោយភាពទទួលខុសត្រូវ និងបច្ចេកវិទ្យាកសិកម្ម)។

សហគ្រិនខ្មែរ (KE) ដែលជាស្ថាប័នមួយស្ថិតនៅក្រោម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចក្ខុវិស័យក្លាយជាវេទិការថ្នាក់ជាតិ សម្រាប់ការលើកកម្ពស់គ្រប់សកម្មភាពរបស់វិស័យសហគ្រិនក្នុងប្រទេសកម្ពុជា។ បេសកម្មរបស់ សហគ្រិនខ្មែរ គឺ ផ្តល់ការគាំទ្រសហថាមពល និងកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព ឱ្យមានភាពរស់រវើក ដែលគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងនវានុវត្តន៍ ការបង្កើនផលិតភាព និងការបង្កើតការងារ។ ដើម្បីសម្រេចបេសកម្មរបស់ខ្លួន សហគ្រិនខ្មែរ ផ្តោតលើកម្មវិធីស្នូលចំនួន៤រួមមាន ការលើកកម្ពស់វប្បធម៌សហគ្រិនភាព, ការអភិវឌ្ឍសមត្ថភាព, បណ្តាញទំនាក់ទំនង និងការផ្តល់មូលនិធិដើមទុន។

ក្នុងដើមឆ្នាំ២០២១ CPSA បានទទួលការគាំទ្រពី សហគ្រិនខ្មែរ តាមរយៈកិច្ចសហការជាដៃគូ ដើម្បីអនុវត្តកម្មវិធីបណ្តុះធុរកិច្ចថ្មី "សហគ្រិនក្នុងសហគមន៍កសិកម្ម "។ កម្មវិធី នេះមានរយៈពេល៣ឆ្នាំ ក្នុងគោលបំណងបង្កើតឧស្សាហកម្មកសិកម្មប្រកបដោយផលិតភាពខ្ពស់ និងមាននិរន្តភាព ដោយធ្វើការជាមួយក្រុមគោលដៅចំនួន២រួមមាន យុវជន និងក្រុមកសិករ។ គម្រោងនេះមានសមាសភាពសំខាន់ៗចំនួន២គឺ ទី១ "ការបណ្តុះ ធុរកិច្ចថ្មី" ដែលយុវជន ត្រូវបានផ្តល់ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម សហគ្រិនភាព និងជំនាញ ធុរកិច្ច ក្នុងរយៈពេល៤ខែ និង ទី២ "ការចុះកម្មសិក្សា" របស់និស្សិត រយៈពេលមួយឆ្នាំ នៅតាមសហគមន៍កសិកម្ម ក្នុងខេត្តគោលដៅដូចជា កំពង់ចាម និងកំពង់ធំ ដើម្បី គាំទ្រកសិករ និងសហគមន៍ជនបទ។

គម្រោងកំពុងធ្វើការជ្រើសរើសសហគ្រិនកសិកម្មវ័យក្មេង ដើម្បីទទួលបានឱកាសបណ្តុះបណ្តាលក្នុងវគ្គបណ្តុះធុរកិច្ចថ្មី និង ការចុះកម្មសិក្សាជាមួយសហគមន៍កសិកម្ម ដែលមានលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

## បេក្ខជនដែលគម្រោងកំពុងស្វែងរក

- និស្សិតឆ្នាំទី៤ ឬទើបតែបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យថ្មីៗ
- មានការតាំងចិត្តខ្ពស់ធ្វើការក្នុងវិស័យកសិកម្ម ធុរកិច្ចកសិកម្ម និងការកែច្នៃចំណីអាហារ

- មានឆន្ទៈធ្វើការជាក្រុម និងជាមួយសហគមន៍នៅតាមជនបទ
- ចង់ក្លាយជាសហគ្រិនកសិកម្ម
- មានគំនិតប្រកបដោយនវានុវត្តន៍ ក្នុងការបង្កើត គំរូ ធុរកិច្ចថ្មីៗក្នុងវិស័យកសិកម្ម
- មានការប្ដេជ្ញាខ្ពស់ក្នុងការរៀនសូត្រ និងចែករំលែកជាមួយសហគមន៍

## លក្ខខណ្ឌក្នុងការជ្រើសរើស

- និស្សិតឆ្នាំទី៤ ឬទើបតែបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យថ្មីៗ
- ជំនាញបច្ចេកទេសកសិកម្ម ការកែច្នៃចំណីអាហារ សេដ្ឋកិច្ចកសិកម្ម ធុរកិច្ចកសិកម្ម ការគ្រប់គ្រងធុរកិច្ច និងផ្នែកពាក់ព័ន្ធដទៃទៀត
- ធ្លាប់ធ្វើការងារ ឬស្ម័គ្រចិត្តជាមួយសហគមន៍ជនបទ
- មានភាពឯករាជ្យ បត់បែន ស្មោះត្រង់ និងជំនាញក្នុងការដោះស្រាយបញ្ហា, និងមានឆន្ទៈរៀនសូត្រ និងចែករំលែកគំនិតធុរកិច្ច, និងបច្ចេកទេសកសិកម្មជាមួយសហគមន៍កសិកម្ម
- មានផ្នត់គំនិតសហគ្រិន ឬក៏ចំណាប់អារម្មណ៍ក្នុងការចូលរួមបង្កើតឲ្យមានបរិយាកាសសហគ្រិនភាព
- មានជំនាញទីផ្សារ ការកសាងបណ្ដាញ ការចចារ និងការតស៊ូមតិ
- មានឆន្ទៈក្នុងការស្នាក់នៅ និងធ្វើការជាមួយសហគមន៍កសិកម្មបន្ទាប់ពីវគ្គហ្វឹកហាត់បានបញ្ចប់
- ទំនាក់ទំនងជាភាសាអង់គ្លេសល្អ និងកំព្យូទ័រ Ms-Office
- និស្សិតដែលកំពុងរស់នៅក្នុងតំបន់ ឬខេត្តគោលដៅដូចជា កំពង់ចាម និងកំពង់ធំ ត្រូវបានលើកទឹកចិត្ត ក្នុងការដាក់ពាក្យសុំ

## អត្ថប្រយោជន៍ និងឱកាសទទួលបាន

- ចំណេះដឹង ជំនាញ និងបទពិសោធ ពីការអនុវត្តផ្ទាល់ ទាក់ទងនឹងបច្ចេកទេសកសិកម្ម សហគ្រិនភាព និងជំនាញការគ្រប់គ្រង ធុរកិច្ច
- ឱកាសរៀនសូត្រពីអ្នកជំនាញ និងអនុវត្តការងារជាក់ស្ដែងក្នុងសហគមន៍កសិកម្ម
- ការគាំទ្រពីគម្រោងក្នុងពេលវគ្គបណ្ដុះបណ្ដាល និង អំឡុងពេលចុះកម្មសិក្សាជាមួយសហគមន៍កសិកម្ម
- បន្តទទួលបានឱកាសប្រឹក្សាយោបល់ និងការណែនាំពីអ្នកជំនាញក្នុងអំឡុងពេលចុះកម្មសិក្សាក្នុងការកសាងទំនាក់ទំនងជាមួយវិស័យឯកជន សង្គមស៊ីវិល និងរដ្ឋាភិបាល តាមរយៈការអភិវឌ្ឍ ធុរកិច្ច និងការស្វែងរកទីផ្សារ សម្រាប់សហគមន៍កសិកម្ម
- អាចក្លាយជាសហគ្រិនក្នុងវិស័យកសិកម្មនាពេលអនាគត

## ពាក្យស្នើសុំ និងសំណួរផ្សេងៗ

- បេក្ខជនអាចទាញយកពាក្យស្នើរសុំនៅទីនេះ៖ http://bit.ly/CPSAstudentapp យកទៅបំពេញ

-

- បន្ទាប់ពីបំពេញរួច បេក្ខជនអាចផ្ញើពាក្យសុំមកកាន់អ៊ីម៉ែល sothearath@cpsakh.org និង cc mao@cpsakh.org; sarin.tey@cpsakh.org
- ឬទាក់ទងទូរស័ព្ទ៖ 096 24 80 795 ( សុខ សុជារតន៍ )

**កាលបរិច្ឆេទផុតកំណត់: ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២១ ម៉ោង៥:០០ល្ងាច**